# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជា៥០ឆ្នាំនៃពាក្យសច្ចារបស់បងស្រីភូឡែត
# ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៨

*ព្រះជាម្ចាស់បង្ហើយអ្វីដែលព្រះជាម្ចាស់បានចាប់ផ្ដើមហើយ!*

អត្ថបទទី១៖ បារ ៥,១-៩
អត្ថបទទី២៖ ភីល ១,៤-៦.៨-១១
ដំណឹងល្អ៖ លក ៣,១-៦

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងសប្បាយចិត្តណាស់ ដោយសារយើងនៅក្នុងរដូវអបអរសាទរព្រះគ្រីស្ដយាងមក។ យើងសប្បាយចិត្តដោយសារ យើងបានស្ដាប់សក្ខីភាពពិសេស ដែលបងស្រីបានផ្ដល់ដល់យើង។ នេះជាកម្លាំងមួយ ព្រោះជាជីវិតពិតៗ មានអំណរសប្បាយផង មានទុក្ខលំបាកផង មានការតស៊ូយ៉ាងច្រើនផង។ ត្រូវដឹងថា នេះជារឿងអាថ៌កំបាំង។ បងស្រីកើតនៅឆ្នាំ១៩៤៨ ដូចម្ដាយខ្ញុំ ហើយខ្ញុំឮថា ពេលម្ដាយខ្ញុំនៅក្មេង គាត់ចង់ធ្វើជាបងស្រី ហើយបងស្រីគាត់ថា ស្ដាយណាស់ ព្រោះស្អាតម៉េចចង់ធ្វើបងស្រី។ ហើយបន្ទាប់មកម្ដាយអត់ជាបងស្រី រៀបការ។

ជីវិតរបស់យើងដឹងថា **ការត្រាស់ហៅរបស់ព្រះជាម្ចាស់ជាអាថ៌កំបាំងមួយ** ដែលយើងត្រូវតែបើកត្រចៀកនិងដួងចិត្ត។ យើងបានស្ដាប់ក្នុងអត្ថបទទី២ លោកប៉ូលនិយាយថា «**ខ្ញុំជឿជាក់ថា ព្រះអង្គដែលបានចាប់ផ្ដើមធ្វើការល្អនៅក្នុងបងប្អូន ទ្រង់ក៏នឹងបង្ហើយការនេះ រហូតដល់ថ្ងៃព្រះគ្រីស្ដយេស៊ូយាងមក**»។ ខ្ញុំគិតថា អ្វីដែលបងស្រីបានឆ្លើយតបទៅព្រះជាម្ចាស់ នៅពេលអាយុ២០ឆ្នាំ បងស្រីថា ឥឡូវនេះខ្ញុំសុខចិត្តធ្វើជាបងស្រីឧបការគុណ បូជាជីវិតអស់មួយជីវិត។ នៅពេលនោះ យើងស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់តាមរបៀបសន្តប៉ូល «**ព្រះអង្គបានចាប់ធ្វើការល្អនៅក្នុងបងប្អូន**»។ ៥០ឆ្នាំព្រះអង្គបានចាប់ផ្ដើមធ្វើការល្អនៅក្នុងបងស្រី។ ប្រសិនបើថ្ងៃណាមួយ ខ្ញុំតែងតាំងឧបដ្ឋាន ឬបូជាចារ្យ ខ្ញុំនិយាយដូច្នេះដែរ «**ឲ្យព្រះជាម្ចាស់បង្ហើយអ្វីដែលព្រះជាម្ចាស់បានចាប់ផ្ដើមហើយ**»។ ជីវិតរបស់យើងគឺហ្នឹង និងសម្រាប់បងប្អូនដែលរៀបការក៏ដូច្នេះដែរ។ បងប្អូនដែលជាតាយាយ សព្វថ្ងៃដឹងហើយ នៅក្នុង២០ ៣០ ៥០ឆ្នាំ ពេលយើងបាននឹកឃើញថ្ងៃដែលយើងបានរៀបការហើយ គឺព្រះជាម្ចាស់បានសាបព្រោះ សេចក្ដីស្រលាញ់ ការត្រាស់ហៅមួយពិសេសដែលល្អ ប៉ុន្តែព្រះជាម្ចាស់ថែរក្សា និងបង្ហើយការនេះ រហូតដល់ថ្ងៃព្រះគ្រីស្ដយេស៊ូយាងមក។ នៅពេលស្ដាប់ប្រវត្តិសាស្ត្របងស្រី គឺហ្នឹង។ ៥០ឆ្នាំ ឧបសគ្គ ទុក្ខលំបាក ជាពិសេសសុខភាពបងស្រី ប៉ុន្តែបងស្រីនៅដើម្បីចែករំលែកអំណរសប្បាយដែលបងស្រីមាន នៅក្នុងការឆ្លើយតបការត្រាស់ហៅរបស់ព្រះជាម្ចាស់។ ហើយសម្រាប់យើងទាំងអស់ ថ្ងៃនេះជាឱកាសមួយដើម្បីរួមជាមួយសន្តប៉ូល ដើម្បីអរព្រះគុណព្រះជាម្ចាស់ ដោយនឹកឃើញជីវិតរបស់យើង នៅពេលយើង

ជ្រើសរើស អ្វីដែលជាសំខាន់បំផុត សម្រាប់អនាគត។ កុំឲ្យយើងចាប់ផ្ដើមសង្ស័យ ភ័យ ខ្លាច ខ្ញុំធ្វើមិនបាន ប្រហែលខ្ញុំអត់មានសមត្ថភាព។ កុំគិតថាព្រះនាងម៉ារីមានសមត្ថភាព ព្រះនាងគ្មានសមត្ថភាពដើម្បីធ្វើមាតារបស់ព្រះជាម្ចាស់។ ប៉ុន្តែ ព្រះនាងម៉ារីទោះបីមិនដឹងច្បាស់ជាក់ស្ដែង គាត់យល់ថានៅក្នុងជំនឿរបស់គាត់ ព្រះជាម្ចាស់បានចាប់ផ្ដើមធ្វើការ និងព្រះជាម្ចាស់ថែរក្សាអស់កល្បជានិច្ច ដើម្បីបង្ហើយអ្វីដែលព្រះជាម្ចាស់ចាប់ផ្ដើមហើយ។ ថ្ងៃនេះ យើងត្រូវតែអរព្រះគុណព្រះជាម្ចាស់ និងអធិដ្ឋានរួមជាមួយសន្តប៉ូលដែរ។ ថ្ងៃនេះ សន្តប៉ូលអធិដ្ឋានដូចតទៅ «**ខ្ញុំទូលអង្វរព្រះជាម្ចាស់ដូចតទៅនេះ គឺសូមឲ្យបងប្អូនមានសេចក្ដីស្រឡាញ់ដ៏លើសលប់**»។ នេះជាការអធិដ្ឋានសម្រាប់បងស្រី និងសម្រាប់មនុស្សទាំងអស់។ អធិដ្ឋានជានិច្ច ដើម្បីឲ្យយើងភ្ជាប់ជាមួយសេចក្ដីស្រឡាញ់ដ៏លើសលប់របស់ព្រះជាម្ចាស់ កាន់តែខ្លាំងឡើងៗ ធ្វើឲ្យបងប្អូនចេះដឹងច្បាស់ និងយល់សព្វគ្រប់ទាំងអស់ ដើម្បីឲ្យបងប្អូនចេះពិចារណាមើលថាការអ្វីប្រសើរជាងគេ គឺការធិដ្ឋាន។

នៅក្នុងរដូវអបអរនេះ យើងអរគុណព្រះជាម្ចាស់ដែលកំពុងយាងមក ដែលកំពុងធ្វើដំណើរជាមួយយើង ដោយដឹងថាព្រះជាម្ចាស់ណែនាំឲ្យអ្វីៗទាំងអស់បង្ហើយនៅថ្ងៃណាមួយ ទោះបីយើងមើលមិនឃើញ និងជួយយើងឈ្នះឧបសគ្គនៅក្នុងជីវិត និងដោយទូលអង្វរព្រះជាម្ចាស់ជានិច្ច។ សូមព្រះអង្គជួយខ្ញុំ ឲ្យខ្ញុំពោរពេញដោយសេចក្ដីស្រឡាញ់ ចំពោះបងប្អូនឯទៀតៗ និងព្រះជាម្ចាស់។ ប៉ុន្តែមិនមែនកើតតែសេចក្ដីស្រឡាញ់តែប៉ុណ្ណឹង គឺត្រូវអនុវត្តនៅក្នុងជីវិតប្រចាំថ្ងៃ និងក្ដីស្រឡាញ់ដែលណែនាំឲ្យយើងចេះមើលអ្វីដែលជាសំខាន់ និងសេចក្ដីត្រូវការសម្រាប់ជីវិតខ្ញុំនិងសម្រាប់បងប្អូនឯទៀតៗ។

រដូវអបអរសាទរ ជាពេលមួយបើកភ្នែកធំណាស់ តើបងប្អូនឯទៀតៗទន្ទឹងរង់ចាំអ្វីខ្លះ? សេចក្ដីត្រូវការអ្វីខ្លះ? ព្រះជាម្ចាស់យាងមកដើម្បីឲ្យយើងមានជីវិត។ ព្រះជាម្ចាស់បានជ្រើសរើសយើង ដើម្បីណែនាំបងប្អូនឯទៀតៗមានជីវិតដ៏បរិបូរណ៍។ នេះជាអ្វីដែលយ៉ូហានបាទីស្ដ បានរៀបចំសម្រាប់យើង យ៉ូហានបាទីស្ដរៀបចំផ្លូវនៃជីវិត ផ្លូវទៅកាន់ជីវិត ដោយកែប្រែចិត្តគំនិត។ យ៉ូហានបាទីស្ដមកដើម្បីធ្វើពិធីជ្រមុជទឹក ឲ្យគេចាប់ផ្ដើមកែប្រែចិត្តគំនិត ប៉ុន្តែព្រះយេស៊ូយាងមកដើម្បី ឲ្យយើងទទួលពិធីជ្រមុជទឹកនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ ដើម្បីណែនាំឲ្យយើងកែប្រែចិត្តគំនិត ឲ្យយើងរស់នៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយអនុវត្តជាក់ស្ដែងពីមួយថ្ងៃទៅមួយថ្ងៃ និងដើម្បីឲ្យមនុស្សទាំងអស់នឹងឃើញការសង្គ្រោះរបស់ព្រះជាម្ចាស់។

គម្រោងការ របស់ព្រះជាម្ចាស់មិនមែនសម្រាប់មនុស្ស៤-៥នាក់នៅក្នុងប្រទេសកម្ពុជា គឺដើម្បីឲ្យមនុស្សទាំងអស់ មើលឃើញការសង្គ្រោះរបស់ព្រះជាម្ចាស់។ នេះជាអ្វីដែលយើងរៀបចំ

នៅក្នុងយប់ដ៏សុខសាន្តបុណ្យព្រះយេស៊ូប្រសូត។ ប្រសិនបើយើងនឹកឃើញ បេថ្លេហឹមកាលពីសម័យដើម គឺប្រជាជន ពួកគង្វាល ហោរាចារ្យដែលទៅមើល ទេវទូតទាំងឡាយ និងមនុស្សនៅស្ថានកណ្ដាល ទាំងអស់គ្នាជុំគ្នាដើម្បីកោតសរសើរព្រះជាម្ចាស់។ ដូច្នេះ យប់បុណ្យព្រះយេស៊ូប្រសូតជាពេលវេលាមួយសម្រាប់យើងដែលជាគ្រីស្តបរិស័ទ ចាប់ពីពេលនេះតទៅ។ ល្ងាចនេះរួមជាមួយពលករនៅគ្រួសារពន្លឺមិត្តភាព គេមិនមែនជាគ្រីស្តបរិស័ទ ប៉ុន្តែគេសប្បាយចិត្តស្ដាប់ដំណឹងល្អ ជីវិតមានអនាគត មានសេចក្ដីសង្ឃឹម។ នៅពេលនេះកំពុងសាងសង់រោងព្រះយេស៊ូមួយយ៉ាងស្អាតណាស់ ខ្ញុំអញ្ជើញលោកឪពុកបើកទ្វារព្រះវិហារ ហើយដាក់ស្លាកហើយសរសេរថា មានរោងព្រះយេស៊ូមួយយ៉ាងស្អាតណាស់ សូមមកមើលទៅ។

យើងទាំងពីរនាក់មកពីភូមិភាគមួយដូចគ្នានៅបារាំង ហើយយើងទទួលតែងតាំងនៅវិសាលវិហារដូចគ្នា ហើយវិសាលវិហារនេះល្បីមែនទែននៅប្រទេសបារាំង កម្ពស់១៤២ម៉ែត្រ អាយុ១០០០ឆ្នាំ ហើយនៅក្នុងវិសាលវិហារនេះ គេមានរោងព្រះយេស៊ូប្រវែង១៨ម៉ែត្រធំណាស់។ ហើយគេបើកទ្វារ និងប្រជាជនមិនមែនកាតូលិក អ៊ីស្លាមផង និងអ្នកភ្លេចសាសនា នៅក្នុងខែធ្នូហ្នឹង គេចេញចូលពីមួយថ្ងៃទៅមួយថ្ងៃដើម្បីថតរូប ពីមួយឆ្នាំទៅមួយឆ្នាំស្អាតទៅៗ។ ឆ្នាំនេះគេដាក់ដើមឈើមួយពិសេស ជាមួយមេអំបៅពណ៌ផ្ទៃមេឃដែលមកកោតសរសើរព្រះនាងម៉ារីនិងយាយអេលីសាបែត។ ប៉ុន្តែចង់និយាយថា នេះសំខាន់ណាស់ ព្រះយេស៊ូយាងមកសម្រាប់មនុស្សទាំងអស់។ ដូច្នេះ ធ្វើយ៉ាងម៉េចដើម្បីឲ្យរោងនេះ និងចិត្តគំនិតរបស់យើងទៅជាសញ្ញាសម្គាល់មួយពិសេស និងយើងសង្ឃឹមបងប្អូនរកផ្លូវចូលដើម្បីមកទីនេះ ដែលជាពន្លឺសម្រាប់បងប្អូនទាំងអស់។ ដូច្នេះយើងសង្ឃឹមនៅក្នុងរដូវអបអរសាទរនេះ បងប្អូនមួយចំនួនអាចរកឃើញផ្លូវដើម្បីចូលនៅទីនេះ ដើម្បីឃើញព្រះយេស៊ូដែលយាងមកសម្រាប់មនុស្សទាំងអស់។

នៅក្នុងរដូវ៤០ថ្ងៃ យើងកែប្រែចិត្តគំនិត យើងមានអារម្មណ៍ថាពិបាក ធ្ងន់ ព្រួយចិត្ត មិនស្រួលនៅក្នុងខ្លួន ដោយនឹកឃើញអំពើបាបរបស់យើង។ នៅក្នុងរដូវអបអរសាទរ រដូវរង់ចាំនេះយើងកែប្រែចិត្តគំនិតដែរ ប៉ុន្តែក្នុងរបៀបផ្សេង នៅក្នុងរបៀបដែលយើងស្ដាប់នៅក្នុងអត្ថបទទី១ « **ក្រុងយេរូសាឡឹមអើយ! ចូរផ្លាស់សម្លៀកបំពាក់កាន់ទុក្ខចេញទៅ ហើយយកសិរីរុងរឿងរបស់ព្រះជាម្ចាស់មកពាក់លំអរជាគ្រឿងអស់កល្បជានិច្ចតរៀងទៅ ចូរយកសេចក្ដីសុចរិតដែលមកពីព្រះជាម្ចាស់មកពាក់ដូចជាអាវធំ**»។ កែប្រែចិត្តគំនិតនៅក្នុងរដូវរង់ចាំ គឺឲ្យយើងយកចេញនូវទុក្ខព្រួយព្រួយបារម្ភ ក្ដីលំបាករបស់យើង ដើម្បីបំពាក់អាវធំថ្មី។ យុត្តិធម៌ សេចក្ដីស្រឡាញ់ សិរីរុងរឿងរបស់ព្រះជាម្ចាស់ ដែលយើងមើលឃើញដល់កំពូលនៅយប់បុណ្យព្រះយេស៊ូប្រសូត។ នៅពេល

យើងច្រៀងសារជាថ្មី សិរីរុងរឿងរបស់ព្រះជាម្ចាស់រួមជាមួយក្រុមទេវទូត។ នេះជាឱកាសមួយ ដើម្បីឲ្យជីវិតរបស់យើង កែប្រែចិត្តគំនិត នៅក្នុងអំណរសប្បាយដ៏ធំធេង។

អាទិត្យក្រោយជាអាទិត្យទី៣ក្នុងរដូវរង់ចាំ ជាអាទិត្យទី៣នៃអំណរសប្បាយ។ ដូច្នេះនៅក្នុងអាទិត្យនេះ សូមកែប្រែចិត្តគំនិត ដើម្បីមានអារម្មណ៍ដូចព្រះនាងម៉ារី ដោយសារបងប្អូនដែលធ្លាប់ធ្វើជាម្តាយដឹងហើយ។ នៅមុនពេលឆ្លងទន្លេ២-៣អាទិត្យមុន ត្រេកអរផងភ័យផង ព្រួយបារម្ភផង ដោយសារបន្តិចទៀតឃើញមុខកូនខ្ញុំពោរពេញដោយអំណរសប្បាយ។ ដូច្នេះយើងត្រូវគិតថា **តើខ្ញុំត្រូវធ្វើអ្វីខ្លះ ដើម្បីស្វាគមន៍ព្រះយេស៊ូនៅក្នុងដួងចិត្តនិងនៅក្នុងជីវិតរបស់ខ្ញុំ?** យើងធ្វើយ៉ាងម៉េចដើម្បីទន្ទឹងរង់ចាំព្រះយេស៊ូដូចគ្នានឹងទន្ទឹងចាំកូនកើតមក ត្រូវរៀបចំចិត្តគំនិតដើម្បីមានចិត្តដ៏បរិសុទ្ធ ដូចក្នុងអត្ថបទទី២ «**ហើយបងប្អូននឹងបានពោរពេញ ដោយផលនៃសេចក្តីសុចរិតដែលមកពីព្រះយេស៊ូគ្រីស្ត សម្រាប់លើកតម្កើងសិរីរុងរឿងនិងកោតសរសើរព្រះជាម្ចាស់**»។ នៅថ្ងៃនេះ បងប្រុស ធឿន នឹងទទួលតែងតាំងជាអ្នកបម្រើអាសនៈជាផ្លូវការ ដើម្បីរៀបចំខ្លួនថែមទៀតក្នុងការត្រាស់ហៅរបស់គាត់ និងកុំព្រួយបារម្ភ ព្រោះអ្វីដែលព្រះជាម្ចាស់បានចាប់ផ្តើមហើយ ព្រះអង្គនឹងណែនាំឲ្យបង្ហើយហើយ។អាម៉ែន៕